# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 789

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការធ្វើឱ្យប្រសើរឡើងការគ្រប់គ្រង និង អភិរក្សធនធានជលផល និងប្រភេទ ធនធាន ជលផល ដែលកំពុងគ្រោះថ្នាក់

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/27 |

៣. ចំណាយគម្រោងសរុប $1,602,800

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | Fisheries Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលជលផល |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនឹងជួយរក្សាបានផលស្តុក ដើម្បីជានាការចាប់ពីធម្មជាតិ សម្រាប់ធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កម្ពុជា។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

Fisheries

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពត, កែប, កោះកុង, កំពង់ធំ, បាត់ដំបង, កំពង់ឆ្នាំង, ពោធិ៍សាត់, បន្ទាយមានជ័យ, ស្ទឹងត្រែង, ក្រចេះ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

- ពង្រឹងការការពារនិងគ្រប់គ្រងទីជម្រកនិងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដើម្បីបង្កើនផលស្តុករបស់វាក្នុងធម្មជាតិឡើងវិញ
- បង្កើតកន្លែងអភិរក្សជលផលនិងពង្រឹងការគ្រប់គ្រងកន្លែងអភិរក្សទាំងអស់នោះ ដើម្បីបង្កើនផលស្តុកធនធានជលផលដែលជាចំណែកជានាការប្រើប្រាស់ធនធានប្រកបដោយនិរន្តភាព។
- បង្កើនការយល់ដឹងដល់គ្រប់ស្រទាប់មហាជនពីសារៈសំខាន់ទីជម្រកនិងកន្លែងអភិរក្សជលផលនិងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដើម្បីកាត់បន្ថយការធ្វើនេសាទល្មើសច្បាប់ និងជំរុញការចូលរួមក្នុងការអភិរក្សធនធានជលផល។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ស្តារឡើងវិញទីជម្រកជលផល

កែលម្អកន្លែងអភិរក្សជលផល រួមទាំងពង្រឹងការងារល្បាត បោះបង្គោលព្រំ ទម្លាក់ប្រអប់ថ្មដើម្បីទប់ស្កាត់ បទល្មើសនិងបង្កើនជម្រកនិងសាសង់ផែល្បាត

ការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចជាផ្សោតទឹកសាប ផ្សោតសមុទ្រ អណ្តើកហ្លួង អណ្តើក សមុទ្រ កន្ធាយក្បាលកង្កែប សេះសមុទ្រ ក្រពើត្រី និងផ្កាថ្ម

បង្កើតនិងគ្រប់គ្រងដែនជម្រកសុវត្ថិភាពជលផលនៅតាមតំបន់ឆ្នេរ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កន្លែងអភិរក្សជលផល រួមទាំងទីជម្រកធនធានជលផល គឺជាទីកន្លែងសម្រាប់ត្រីមេពូជនិងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់រស់នៅ និងបន្តពូជ។ ដូច្នេះ បើការការពារនិងគ្រប់គ្រងកន្លែងទាំងអស់នេះមិនបានល្អទេនោះ ផលស្តុកធនធានជលផលនៅក្នុងធម្មជាតិនឹងមានការថយចុះ ដែលនឹងជះឥទ្ធិពលដល់ផលិតភាពនៅក្នុងធម្មជាតិ ហើយទីបំផុតនឹងប៉ះពាល់ដល់ផលចាប់ ដែលជាប្រភពម្ហូបអាហារប្រចាំថ្ងៃនិងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកនេសាទ មន្ត្រីជលផល និងអាជ្ញាធរមូលដ្ឋាន

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**មិនមានផលប៉ះពាល់ណាមួយរបស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញតំបន់អនុវត្តគម្រោងនោះទេ មិនតែប៉ុណ្ណោះគម្រោងបានរួមចំណែកដល់សន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គមនិងការអភិវឌ្ឍប្រទេស។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការចូលរួមអនុវត្តគម្រោងទៅតាមជំនាញនិងបទពិសោធន៍ដែលធ្លាប់មាន។ គោលដៅគម្រោងជម្រុញឲ្យមានការចូលរួមពីស្ត្រីយ៉ាងតិច៤០%។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

- **មន្ត្រីអនុវត្តការងារមានចំនួនគ្រប់គ្រាន់និងប្រកបដោយសមត្ថភាព**
- **មានកិច្ចសហការល្អជាមួយមន្ត្រីថ្នាក់ក្រោមជាតិ អាជ្ញធរ និងសហគមន៍មូលដ្ឋាន។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**កន្លងមកការអនុវត្តគម្រោងប្រព្រឹត្តទៅបានល្អ ទាំងនេះដោយរដ្ឋបាលជលផលមានមន្ត្រីដែលមានជំនាញគ្រប់គ្រាន់និងបទពិសោធន៍ការងារ រួមទាំងការផ្តល់ថវិកាទាន់ពេល។ ប៉ុន្តែគម្រោងនឹងជួបហានិភ័យ ប្រសិនបើមន្ត្រីមិនមានឆន្ទៈបំពេញការងារ ឬ ភាពអសកម្មរបស់មន្ត្រីអនុវត្តការងារនិងកង្វះកិច្ចសហការល្អជាមួយមន្ត្រីថ្នាក់ក្រោមជាតិ អាជ្ញធរ និងសហគមន៍មូលដ្ឋាន រួមទាំងមិនមានថវិកាគ្រប់គ្រាន់ ឬការផ្តល់ថវិកាឲ្យមិនទាន់ពេលវេលា...ជាដើម។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

ពីមុនក៏ដូចបច្ចុប្បន្ន ក្រៅពីប្រភពថវិការបស់រាជរដ្ឋាភិបាល
នៅមានការចូលរួមគាំទ្រពីដៃគូអភិវឌ្ឍមួយចំនួននៅបន្តជួយលើសកម្មភាពអភិរក្សធនធានជលផល
ប៉ុន្តែថវិកាទាំងនេះមិនអាចបំពេញបានគ្រប់ទៅតាមទំហំការងារនោះទេ។ ដៃគូអភិវឌ្ឍទាំងនោះមានដូចជា អង្គការWWF
SEAFDEC/GEF, IUCN,KFW, Mekong-Lanchang និងEU..ជាដើម។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 180.8 | 170.0 | 175.0 | 525.8 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 10.8 | 0.0 | 0.0 | 10.8 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 25.0 | 65.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 150.0 | 150.0 | 150.0 | 450.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 357.0 | 360.0 | 360.0 | 1,077.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 250.0 | 250.0 | 250.0 | 750.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 7.0 | 5.0 | 5.0 | 17.0 | 0.0 |
| ទព្វសម្ភារ: | 0.0 | 0.0 | 0.0 | 25.0 | 25.0 | 25.0 | 75.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 50.0 | 55.0 | 55.0 | 160.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 25.0 | 25.0 | 25.0 | 75.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 537.8 | 530.0 | 535.0 | 1,602.8 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Other | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 537.8 | 530.0 | 535.0 | 1,602.8 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: